ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាអាជ្ញាកណ្តាល
THE ARBITRATION COUNCIL

លេខ និង ឈ្មោះសំណុំរឿង ៖ ០៥០/១៧ - យ៉ាប ឌីហ្សាញ លីមីធីត

កាលបរិច្ឆេទនៃសេចក្តីបង្គាប់ ៖ ថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០១៨

# សេចក្តីបង្គាប់អាជ្ញាកណ្តាល

(ធ្វើឡើងស្របតាមមាត្រា ៣១៣ នៃច្បាប់ស្តីពីការងារ)

## សមាសភាពក្រុមអាជ្ញាកណ្តាល

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីនិយោជក ៖ **ម៉ារ សំបូរណា**

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត ៖ **អន ណន**

ប្រធានក្រុមអាជ្ញាកណ្តាលជ្រើសរើសឡើងដោយអាជ្ញាកណ្តាលទាំងពីរខាងលើ ៖ **សុខ ម៉ាធឿង**

## ភាគីនៃវិវាទ

### ១- ភាគីនិយោជក

ឈ្មោះ ៖ **ក្រុមហ៊ុន យ៉ាប ឌីហ្សាញ លីមីធីត**

អាសយដ្ឋាន ៖ ភូមិត្រពាំងក្រសាំង ឃុំបែកចាន ស្រុកអង្គស្នួល ខេត្តកណ្តាល

ទូរស័ព្ទ ៖ ០៧០ ៥០៤ ៤០៥ ទូរសារ ៖ គ្មាន

តំណាងភាគីនិយោជក ៖

| | |
|---|---|
| ១- កញ្ញា ឌឹម ម៉ាឡែន | ប្រធានធនធានមនុស្ស |
| ២- លោកស្រី មួន សុលីតា | ជំនួយការរដ្ឋបាល |
| ៣- លោកស្រី នាក់ សង្វាវ៉ាន់ | គណនេយ្យ |

### ២- ភាគីកម្មករនិយោជិត

ឈ្មោះ ៖ - **អ្នកតំណាងភាគីកម្មករនិយោជិតក្នុងការដោះស្រាយវិវាទការងាររួម នៃក្រុមហ៊ុន យ៉ាប ឌីហ្សាញ លីមីធីត**

អាសយដ្ឋាន ៖ ភូមិត្រពាំងក្រសាំង ឃុំបែកចាន ស្រុកអង្គស្នួល ខេត្តកណ្តាល

ទូរស័ព្ទ ៖ ០១៥ ៨៧ ២២ ៩៦ ទូរសារ ៖ គ្មាន

តំណាងកម្មករនិយោជិត ៖

| | |
|---|---|
| ១- លោក ខោល សុខេម | តំណាងកម្មករ |

ផ្ទះលេខ ៧២ ផ្លូវលេខ ៥៩២ (កែងផ្លូវលេខ ៣២៧) សង្កាត់បឹងកក់ ២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។ ទូរស័ព្ទ/ទូរសារ: ៨៥៥.២៣ ៨៨១ ៨២៤
No. 72, Street 592 (corner of St. 327), Sangkat Boeung Kak II, Khan Toul Kork, Phnom Penh + Tel/Fax: 855-23 881 824
E-mail: secretariat@arbitrationcouncil.org + Website: www.arbitrationcouncil.org

២- លោក អ៊ុន សុងឡេង ផ្នែកកាតុង

៣- លោក ធន់ ផាន្នា ប្រធានផ្នែកទូទៅ

៤- លោក កើត សុខឡេង ផ្នែកវេចខ្ចប់

៥- លោក វ៉ន រតនៈ បើកកង់បី

៦- លោក សាយ ទុំ អ្នកខាត់

៧- លោក ជា សុជាតិ ផ្នែកលាបពណ៌

៨- លោកស្រី រស់ ស្រីនិត ផ្នែកលាបពណ៌

៩- កញ្ញា ប៉ោ ស្រីពៅ ផ្នែកលាបពណ៌

១០- លោកស្រី ធឿន ម៉ារី ផ្នែកលាបពណ៌

## បញ្ហាក្នុងវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

១- បងប្អូនកម្មករទាមទារឱ្យនិយោជកបើកប្រាក់ឈ្នួល ខែតុលា នៅខ្វះ ៥០% និងខែវិច្ឆិកា ឆ្នាំ២០១៧ ដែលពុំទាន់បានបើក ១០០%។ ភាគីក្រុមហ៊ុនពុំមានលុយបើកជូនទេ ដោយសារក្រុមហ៊ុនផលិតមិនគ្រប់ចំនួន ហើយចំណាយច្រើនជាងចំណូល ហេតុដូច្នេះហើយ ក្រុមហ៊ុនពុំមានលុយបើកជូនបងប្អូនកម្មករឡើយ។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្ដាល

ក្រុមប្រឹក្សាអាជ្ញាកណ្ដាលទទួលអំណាចក្នុងការចេញសេចក្ដីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែកទីពីរ (ខ) (មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្ដីពីការងារឆ្នាំ១៩៩៧ ប្រកាសស្ដីពីក្រុមប្រឹក្សាអាជ្ញាកណ្ដាលលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្ដាល ដែលភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ និងប្រកាសស្ដីពីការតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្ដាលលេខ ២០៨ ក.ប/ប្រ.ក.វ.ក ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៧ (អាណត្តិទី១៥)។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្ដីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី១២ ផ្នែកទី២ (ក) នៃច្បាប់ស្ដីពីការងារ។ ប៉ុន្ដែ ការផ្សះផ្សានោះ ភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ ហើយរបាយការណ៍ស្ដីអំពីការដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុន យ៉ាប ឌីហ្សាញ លីមីធីត លេខ ០៧៦/១៧ ក.ប/កណ ចុះថ្ងៃអង្គារ ២កើត ខែបុស្ស ឆ្នាំរកា ព.ស ២៥៦១ ត្រូវនឹងថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៧ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្ដាល នៅថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៧។

**សវនាការ និង សង្ខេបនីតិវិធី**

**ទីកន្លែងសវនាការ ៖** ក្រុមប្រឹក្សាអាជ្ញាកណ្ដាល ភូមិគ្រឹះលេខ ៧២ ផ្លូវលេខ ៥៩២ កាច់ជ្រុងផ្លូវលេខ ៣២៧ (ទល់មុខវិទ្យាល័យឥន្ទ្រទេវី), សង្កាត់បឹងកក់ ២, ខណ្ឌទួលគោក, រាជធានីភ្នំពេញ ។

THE ARBITRATION COUNCIL

កាលបរិច្ឆេទសវនាការ ៖ ថ្ងៃព្រហស្បតិ៍ ៤កើត ខែបុស្ស ឆ្នាំរកា ព.ស២៥៦១ ត្រូវនឹងថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៧ (វេលាម៉ោង ១៤ និង ០០ នាទី រសៀល) ។

**បញ្ហានីតិវិធី៖**

នៅថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៧ មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តកណ្តាល បានទទួលពាក្យបណ្តឹងរបស់កម្មករនិយោជិត ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៧ ស្តីពីការទាមទារបើកប្រាក់ឈ្នួលសម្រាប់ខែតុលា និងខែវិច្ឆិកាក្នុងឆ្នាំ២០១៧។ បន្ទាប់ពីទទួលពាក្យបណ្តឹងនេះមក មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តកណ្តាល បានចាត់មន្ត្រីជំនាញឱ្យធ្វើការដោះស្រាយ និងធ្វើការផ្សះផ្សាវិវាទការងារនេះ ចំនួន ១ ចំណុច នៅថ្ងៃទី១៨ ខែធ្នូ ឆ្នាំ ២០១៧ ដោយមិនទទួលបានលទ្ធផលសះជានឹងគ្នាទេ។ ចំណុចមិនសះជាដែលនៅសល់ ចំនួន ១ ចំណុច ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៧ តាមរយៈរបាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន យ៉ាប ឌីហ្សាញ លីមីធីត លេខ ០៧៦/១៧ ក.ប/កណ ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៧។

បន្ទាប់ពីបានទទួលសំណុំរឿងនេះ ក្រុមអាជ្ញាកណ្តាលត្រូវបានបង្កើតឡើងនៅថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៧។ លេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល បានធ្វើការកោះអញ្ជើញភាគីនិយោជក និងភាគីកម្មករនិយោជិត មកសវនាការ និងធ្វើការផ្សះផ្សាលើករណីមិនសះជា ចំនួន ១ ចំណុច នៅថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១៧ វេលាម៉ោង ០២ និង ០០ នាទី រសៀល។ ភាគីទាំងពីរ មានវត្តមាននៅក្នុងសវនាការ តាមការអញ្ជើញរបស់លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានព្យាយាមសួររកនូវអង្គហេតុផ្សេងៗ ដែលទាក់ទងទៅនឹងចំណុចវិវាទដែលនៅសល់ ចំនួន ១ ចំណុចនេះ និងបានធ្វើការផ្សះផ្សាលើចំណុចមិនសះជានេះបន្ថែមទៀត ដោយមិនទទួលបានលទ្ធផលសះជានឹងគ្នានោះទេ។ ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងធ្វើការពិចារណាចំណុចវិវាទ ចំនួន ១ ចំណុចនេះ គឺចំណុចវិវាទទី១។

នៅក្នុងសំណុំរឿងនេះ ភាគីជ្រើសរើសសេចក្តីបង្គាប់មិនជាប់កាតព្វកិច្ច។

កាលបរិច្ឆេទនៃការចេញសេចក្តីបង្គាប់អាជ្ញាកណ្តាល គឺថ្ងៃទី១១ ខែមករា ឆ្នាំ២០១៨។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណា និងដោះស្រាយលើចំណុចវិវាទខាងលើនេះ ដោយផ្អែកលើភស្តុតាង និងការរកឃើញនៃអង្គហេតុ ដូចខាងក្រោម ៖

## ភស្តុតាង

សាក្សី និង អ្នកជំនាញក្រៅពីភាគី ៖ គ្មាន

## ឯកសារ វត្ថុតាង ដែលក្រុមអាជ្ញាកណ្តាលយកមកពិចារណាមាន

ក- ឯកសារបានទទួលពីភាគីនិយោជក ៖

១- លិខិតផ្ទេរសិទ្ធិ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៧ របស់នាយកសហគ្រាសឃីហោ យ៉ាប ឌីហ្សាញ លីមីធីត គោរពជូន ប្រធានលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល ស្តីពីសុំផ្ទេរសិទ្ធិជូន លោកស្រី ឌឹម ម៉ាឡែន។

THE ARBITRATION COUNCIL

២- វិញ្ញាបនបត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មក្រុមហ៊ុន យ៉ាប ឌីហ្សាញ លីមីធីត លេខ ៧២៩៨ ពណ.ចបព ចុះថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០១៥។

៣- លក្ខន្តិកៈក្រុមហ៊ុន យ៉ាប ឌីហ្សាញ លីមីធីត បានតំកល់ទុកលេខ ២១៨៩/២០១៥ ពណ.ចបព ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១៥ នៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម។

៤- បទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុន យ៉ាប ឌីហ្សាញ លីមីធីត បានឃើញ និងបញ្ជាក់ថាត្រឹមត្រូវ លេខ ១១៣៧ ប.ក.វ ថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៧ ដោយប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តកណ្តាល។

ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត ៖គ្មាន

គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

១- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន យ៉ាប ឌីហ្សាញ លីមីធីត លេខ ០៧៦/១៧ ក.ប/កណ ចុះថ្ងៃអង្គារ ២កើត ខែបុស្ស ឆ្នាំរកា ព.ស ២៥៦១ ត្រូវនឹងថ្ងៃទី១៩ ខែធ្នូ ឆ្នាំ ២០១៧។

២- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមនៅក្រុមហ៊ុន យ៉ាប ឌីហ្សាញ លីមីធីត ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៧។

៣- លិខិតបញ្ជាក់អ្នកតំណាងភាគីកម្មករនិយោជិតក្នុងការដោះស្រាយវិវាទការងាររួម នៃក្រុមហ៊ុន យ៉ាប ឌីហ្សាញ លីមីធីត លេខ ០១៣ ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៧ របស់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តកណ្តាល។

ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល

១- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការលេខ ៣៨៤ កប/អក/វក/លកអ. ចុះថ្ងៃព្រហស្បតិ៍ ០៤ កើត ខែបុស្ស ឆ្នាំរកា នព្វស័ក ព.ស២៥៦១ ត្រូវនឹងថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១៧។

២- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការលេខ ៣៨៥ កប/អក/វក/លកអ. ចុះថ្ងៃព្រហស្បតិ៍ ០៤កើត ខែបុស្ស ឆ្នាំរកា នព្វស័ក ព.ស២៥៦១ ត្រូវនឹងថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១៧។

**អង្គហេតុ**

- ក្រោយពីបានពិនិត្យរបាយការណ៍នៃការផ្សះផ្សាវិវាទការងាររួម
- ក្រោយពីបានស្តាប់អំណះអំណាងរបស់តំណាងភាគីកម្មករនិយោជិត និងនិយោជក
- ក្រោយពីបានពិនិត្យឯកសារបន្ថែម

**ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា ៖**

- ក្រុមហ៊ុន យ៉ាប ឌីហ្សាញ លីមីធីត តទៅនេះហៅថា "ក្រុមហ៊ុន យ៉ាប ឌីហ្សាញ" គឺជាក្រុមហ៊ុនដែលមានសកម្មភាពចម្បងក្នុងការផលិតគ្រឿងសង្ហារិម គ្រឿងតុបតែងលម្អ និងរូបចម្លាក់ និងបានទទួលវិញ្ញាបនប-

THE ARBITRATION COUNCIL

បត្របញ្ជាក់ការចុះបញ្ជីពាណិជ្ជកម្មក្រោមលេខ Co. ១៥២៥ E/២០១៥ ចុះថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០១៥។ បច្ចុប្បន្នក្រុមហ៊ុននេះ ជួលកម្មករនិយោជិតចំនួនប្រហែលជា ១៩៨ នាក់ *(យោងតាមរបាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន យ៉ាប ឌីហ្សាញ លីមីធីត)* ។

- នៅក្នុងសវនាការ ភាគីទាំងពីរមិនបានលើកឡើងថា នៅក្នុងក្រុមហ៊ុន យ៉ាប ឌីហ្សាញ មានសហជីពដែលមានភាពតំណាងបំផុតនោះទេ។
- មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តកណ្តាល បានចេញលិខិតបញ្ជាក់អ្នកតំណាងភាគីកម្មករនិយោជិត ក្នុងការដោះស្រាយវិវាទការងាររួម លេខ ០១៣ ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៧ ដែលមានឈ្មោះ ១. ខោល សុខេម ២. អ៊ុន សុងឡេង និង ៣. ធន់ ផន្នា ជាអ្នកតំណាងភាគីកម្មករនិយោជិត នៃសហគ្រាសគ្រឹះស្ថានឈ្មោះ យ៉ាប ឌីហ្សាញ លីមីធីត ដើម្បីដោះស្រាយវិវាទការងាររួមនៃសំណុំរឿងលេខ ០៧៦ ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៧។
- នៅថ្ងៃសវនាការ កម្មករនិយោជិតទាំង ៣ នាក់ខាងលើ មានវត្តមាននៅក្នុងសវនាការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល។

**ចំណុចវិវាទទី ១ ៖ *ភាគីកម្មករនិយោជិតទាមទារឱ្យនិយោជកបើកប្រាក់ឈ្នួលសម្រាប់ខែតុលា ដែលនៅខ្វះចំនួន ៥០ ភាគរយ និងខែវិច្ឆិកា ឆ្នាំ២០១៧ ដែលពុំទាន់បានបើកចំនួន ១០០ ភាគរយ***

- *ភាគី*ទាំងពីរទទួលស្គាល់ថា និយោជកមិនទាន់បានបើកប្រាក់ឈ្នួលជូនកម្មករនិយោជិត ចំនួន ១៨១ នាក់ សម្រាប់ខែតុលា ឆ្នាំ២០១៧ ដែលនៅខ្វះចំនួន ៥០ ភាគរយ និងខែវិច្ឆិកា ឆ្នាំ២០១៧ ដែលនៅខ្វះចំនួន ១០០ ភាគរយ។
- *ភាគី*និយោជកបានបញ្ជាក់ថា ៖
    - និយោជកមានឆន្ទៈបើកប្រាក់ឈ្នួលជូនកម្មករនិយោជិត ហើយក៏មិនមានគម្រោងបិទក្រុមហ៊ុនដើម្បីគេចចេញពីការទទួលខុសត្រូវក្នុងការបើកប្រាក់ឈ្នួលជូនកម្មករនិយោជិតនោះដែរ។
    - និយោជកមិនអាចបញ្ជាក់ពីពេលវេលាកំណត់ជាក់លាក់ ដែលនិយោជកអាចបើកប្រាក់ឈ្នួល ជូនកម្មករនិយោជិតបានទេ ពីព្រោះ និយោជកមិនមានលទ្ធភាព ហើយបច្ចុប្បន្ននិយោជកកំពុងនៅបរទេសហើយក៏កំពុងរង់ចាំប្រាក់ ដែលបានមកពីការលក់ភាគហ៊ុន ចំនួន ២៥ ភាគរយ របស់ក្រុមហ៊ុនទៅឱ្យដៃគូវិនិយោគថ្មី មកពីប្រទេសអូស្ត្រាលី ដើម្បីយកមកបើកប្រាក់ឈ្នួលជូនកម្មករនិយោជិត។
- *ភាគី*កម្មករនិយោជិតបានលើកឡើងថា កម្មករនិយោជិតមានការលំបាកនៅពេលដែលនិយោជកមិនបានបើកប្រាក់ឈ្នួលជូនកម្មករនិយោជិត ដោយបច្ចុប្បន្នកម្មករនិយោជិតកំពុងជំពាក់បំណុលគេ។

**ហេតុផលនៃសេចក្តីសម្រេច ៖**

មុននឹងពិចារណាលើការទាមទារ ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណាអំពីដើមបណ្តឹង នៅក្នុងសំណុំរឿងនេះដូចខាងក្រោម ៖

កថាខណ្ឌទី១ មាត្រា ៥៤ នៃច្បាប់ស្តីពីសហជីព ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៦ ចែងថា ៖ *"ភាពជា*

THE ARBITRATION COUNCIL

*តំណាងបំផុតនៃសហជីពត្រូវបានទទួលស្គាល់នៅក្នុងក្របខ័ណ្ឌនៃសហគ្រាស ឬគ្រឹះស្ថាន។ សម្រាប់គោលបំណងនៃការចរចាអនុសញ្ញារួម ឬដោះស្រាយវិវាទការងាររួម គឺសហជីពដែលមានភាពជាតំណាងបំផុតទទួលបានសិទ្ធិផ្តាច់មុខ។"* ។

យោងតាមកថាខណ្ឌទី១ មាត្រា ៥៤ នៃច្បាប់ស្តីពីសហជីពខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា មានតែសហជីពដែលមានភាពជាតំណាងបំផុតប៉ុណ្ណោះ ដែលមានសិទ្ធិផ្តាច់មុខនៅក្នុងការចរចាបង្កើតអនុសញ្ញារួម និងដោះស្រាយវិវាទការងាររួម។ សិទ្ធិផ្តាច់មុខក្នុងការដោះស្រាយវិវាទការងាររួមនេះ សំដៅលើសិទ្ធិក្នុងការនាំយកវិវាទ និងធ្វើជាតំណាងឱ្យកម្មករនិយោជិតនៅគ្រប់នីតិវិធីដោះស្រាយវិវាទការងាររួម ដោយរួមបញ្ចូលទាំងនីតិវិធីដោះស្រាយវិវាទនៅក្រុមប្រឹក្សាអាជ្ញាកណ្តាលផងដែរ។ *(សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាល លេខ ១៧១/១៦-ដេវើលីន ខូអិលធីឌី, លេខ ១៨៣/១៦-យីដា មេនូហ្វេកធីរី ខូអិលធីឌី, ១៨៤/១៦-ឃ្វីនធ៍ មេជើរ អ៊ិនដាស្ទ្រៀល ខូអិលធីឌី និង លេខ ០០១/១៧-ដាយអឹម៉ិន ស៊ីធី ប្រាយវេត លីមីធីត ខមភេនី)*

ក្រុមប្រឹក្សាអាជ្ញាកណ្តាលក្នុងសំណុំរឿងនេះ ក៏យល់ស្របទទួលយកហេតុផល និងការបកស្រាយរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលក្នុងសំណុំរឿងមុនៗ ខាងលើដែរ។

ទោះជាយ៉ាងណា យោងតាមអង្គហេតុ ភាគីទាំងពីរមិនបានបញ្ជាក់ថានៅក្នុងក្រុមហ៊ុន យ៉ាប ឌីហ្សាញ មានសហជីពដែលមានភាពជាតំណាងបំផុតនៅឡើយទេ។

ទន្ទឹមគ្នានេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងលេខ ១៨០/១៦-ស៊ីម៉ង់តិ៍ កម្ពុជា ចក្រីទីង បានបកស្រាយថា ៖ *"...អវត្តមាននៃសហជីពដែលមានភាពជាតំណាងបំផុតនេះ អាចបណ្តាលឱ្យមានភាពរាំងស្ទះដល់សិទ្ធិតំណាងសម្រាប់កម្មករនិយោជិតក្នុងការដោះស្រាយវិវាទការងាររួម និងអាចធ្វើឱ្យប៉ះពាល់ដល់សិទ្ធិមូលដ្ឋានក្នុងការប្តឹងតវ៉ា ឬទាមទារសំណង ដែលផ្តល់ឱ្យកម្មករនិយោជិតដោយរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។*

*...ក្នុងករណីដែលសហគ្រាស ឬគ្រឹះស្ថានមួយមិនទាន់មានអត្ថិភាពនៃសហជីពដែលមានភាពជាតំណាងបំផុត កម្មករនិយោជិតដែលជាប់ពាក់ព័ន្ធក្នុងវិវាទមានសិទ្ធិតំណាងដោយផ្ទាល់ខ្លួន ឬមានសិទ្ធិក្នុងការពឹងពាក់ ឬផ្ទេរសិទ្ធិជូនសហជីពមូលដ្ឋាន ឬបុគ្គលផ្សេងទៀត ដើម្បីធ្វើជាតំណាងរបស់ខ្លួនក្នុងការដោះស្រាយវិវាទការងាររួមនៅក្រុមប្រឹក្សាអាជ្ញាកណ្តាល ប្រសិនបើពួកគាត់យល់ថា សិទ្ធិរបស់ពួកគាត់ត្រូវបានបំពានដោយនិយោជក។"* ។ *(សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ ១៧១/១៦-ដេវើលីន ខូអិលធីឌី, លេខ ១៨៣/១៦-យីដា មេនូហ្វេកធីរី ខូ អិលធីឌី, លេខ ១៨៨/១៦-ហ្គ្រីន សាំមីត (ខេមបូឌា) លីមីធីត, លេខ ១៩៧/១៦-ស៊ីន ជីធាន (ខេមបូឌា) និងលេខ ២១០/១៦-ហ្គ្រេត អនទើរ ថេកស្តាយ ហ្វេកធើរី លីមីធីត)*

ក្រុមប្រឹក្សាអាជ្ញាកណ្តាលក្នុងសំណុំរឿងនេះ ក៏យល់ស្របទទួលយកហេតុផល និងការបកស្រាយរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលក្នុងសំណុំរឿងមុនៗខាងលើដែរថា កម្មករនិយោជិតនឹងមិនអាចនាំវិវាទការងាររួមមកដោះស្រាយបានទេ នៅពេលដែលមិនមានសហជីពដែលមានភាពជាតំណាងបំផុតនៅក្នុងក្រុមហ៊ុន។ ហេតុនេះ កម្មករនិយោជិតគួរមានសិទ្ធិពឹងពាក់សហជីព ឬនាំវិវាទមកដោយផ្ទាល់ ឬផ្ទេរសិទ្ធិជូនបុគ្គលណាផ្សេងទៀតដែលមានសិទ្ធិស្របច្បាប់ក្នុងការតំណាងដើម្បីមកដោះស្រាយវិវាទការងាររួម រាប់ទាំងនៅដំណាក់កាលក្រុមប្រឹក្សាអាជ្ញាកណ្តាលផងដែរ។

THE ARBITRATION COUNCIL

ប្រការ១ នៃប្រកាសលេខ ៣៦២ ក.ប/ប្រ.ក ស្ដីពីការធ្វើប្រតិភូកម្មមុខងារក្នុងការធ្វើបណ្ដឹងអំពីវិវាទការងាររួម និងចេញលិខិតទទួលស្គាល់ប្រតិភូក្រុមប្រឹក្សាចរចា ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៦ របស់ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ ចែងថា ៖ " *ត្រូវបានធ្វើប្រតិភូកម្មជូនដល់ប្រធាននាយកដ្ឋានវិវាទការងារ និងប្រធានមន្ទីរការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈខេត្ត នូវមុខងារ ដូចខាងក្រោម ៖*

...

- *ចេញលិខិតទទួលស្គាល់ប្រតិភូក្រុមប្រឹក្សាចរចា សម្រាប់ដោះស្រាយវិវាទការងាររួម ។*" ។

យោងតាមប្រការ ១ នៃប្រកាសលេខ ៣៦២ ក.ប/ប្រ.ក ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលយល់ថា នាយកដ្ឋានវិវាទការងារ និងប្រធានមន្ទីរការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈខេត្ត មានមុខងារក្នុងការទទួលស្គាល់កម្មករនិយោជិត ឱ្យធ្វើជាតំណាងរបស់ភាគីកម្មករនិយោជិត ដើម្បីដោះស្រាយវិវាទការងាររួម។ ដូច្នេះ កម្មករនិយោជិតដែលត្រូវបានទទួលស្គាល់ដោយនាយកដ្ឋានវិវាទការងារ ឬប្រធានមន្ទីរការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈខេត្ត មានសិទ្ធិស្របច្បាប់ក្នុងការតំណាងឱ្យភាគីកម្មករនិយោជិត ដើម្បីដោះស្រាយវិវាទការងាររួម ដោយរួមទាំងនៅដំណាក់កាលដោះស្រាយវិវាទការងារនៅក្រុមប្រឹក្សាអាជ្ញាកណ្ដាលផងដែរ នៅពេលមិនទាន់មានសហជីពដែលមានភាពជាតំណាងបំផុត។ *(សូមមើលសេចក្ដីសម្រេចអាជ្ញាកណ្ដាល លេខ ២២៧/១៦-យូនីកតា ថេកណេឡូជី (ខេមបូឌា), លេខ ២២៤/១៦-កាស៊ីណូកោះមាស និង សណ្ឋាគារ, លេខ ០០៨/១៧-ថបវើលដ៍ ហ្គាមិន (ខេមបូឌា) អិលធីឌី និង លេខ ២៣៧/១៦-ហ្សិណា-ដាយដុង (ខេមបូឌា) អេឡិចត្រូនិច)*

ក្រុមប្រឹក្សាអាជ្ញាកណ្ដាលនៅក្នុងសំណុំរឿងនេះ ក៏យល់ស្របទទួលយកហេតុផល និងការបកស្រាយរបស់ក្រុមប្រឹក្សាអាជ្ញាកណ្ដាលនៅក្នុងសំណុំរឿងមុនៗ ខាងលើដែរ។

យោងតាមលិខិតបញ្ជាក់អ្នកតំណាងភាគីកម្មករនិយោជិត ក្នុងការដោះស្រាយវិវាទការងាររួម របស់មន្ទីរការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈខេត្តកណ្ដាល ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលរកឃើញថា មន្ទីរការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈខេត្តកណ្ដាល បានទទួលស្គាល់កម្មករនិយោជិត ចំនួន ៣ នាក់ គឺ ១. ខោល សុខេម ២. អ៊ុន សុងឡេង និង ៣. ធន់ ផន្នា ឱ្យធ្វើជាតំណាងភាគីកម្មករនិយោជិត នៅក្នុងសំណុំរឿងនេះស្របតាមប្រកាសលេខ ៣៦២ ក.ប/ប្រ.ក ខាងលើ។ កម្មករនិយោជិតទាំង ៣ នាក់ខាងលើ មានវត្តមាននៅក្នុងសវនាការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្ដាលដែរ។ ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលយល់ឃើញថា កម្មករនិយោជិតទាំង ៣ នាក់ ដែលមានឈ្មោះនៅក្នុងលិខិតបញ្ជាក់អ្នកតំណាង និងមានវត្តមាននៅក្នុងសវនាការ មានសិទ្ធិក្នុងការតំណាងឱ្យកម្មករនិយោជិត នៃក្រុមហ៊ុន យ៉ាប ឌីហ្សាញ ក្នុងការដោះស្រាយវិវាទការងាររួមនៅក្រុមប្រឹក្សាអាជ្ញាកណ្ដាល ស្របតាមប្រការ១ នៃប្រកាសលេខ ៣៦២ ក.ប/ប្រ.ក ខាងលើ។

**ចំណុចវិវាទទី ១ ៖ ភាគីកម្មករនិយោជិតទាមទារឱ្យនិយោជកបើកប្រាក់ឈ្នួលសម្រាប់ខែតុលា ដែលនៅខ្វះចំនួន ៥០ ភាគរយ និងខែវិច្ឆិកា ឆ្នាំ២០១៧ ដែលពុំទាន់បានបើកចំនួន ១០០ ភាគរយ**

ក្រុមប្រឹក្សាអាជ្ញាកណ្ដាលពិចារណាថា តើនិយោជកមានកាតព្វកិច្ចបើកប្រាក់ឈ្នួលសម្រាប់ខែតុលា ដែលនៅខ្វះ ៥០ ភាគរយ និងខែវិច្ឆិកា ឆ្នាំ២០១៧ ដែលពុំទាន់បានបើក ១០០ ភាគរយ ជូនកម្មករនិយោជិតដែរ ឬទេ?

តាមរយៈអង្គហេតុខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា ភាគីទាំងពីរបានទទួលស្គាល់ថា និយោជក មិនទាន់បានបើកប្រាក់ឈ្នួលជូនកម្មករនិយោជិត ចំនួន ១៨១ នាក់ សម្រាប់ខែតុលា ឆ្នាំ២០១៧ ចំនួន ៥០ ភាគរយ និងសម្រាប់ខែវិច្ឆិកា ឆ្នាំ២០១៧ ចំនួន ១០០ ភាគរយ។ ភាគីនិយោជកបានបញ្ជាក់ពីមូលហេតុនៃការមិនទាន់បាន បើកប្រាក់ឈ្នួលជូនកម្មករនិយោជិតនេះថា និយោជកមានបញ្ហាហិរញ្ញវត្ថុ ហើយបានសម្រេចលក់ភាគហ៊ុនជូនដៃគូ វិនិយោគបរទេសមួយនៅអូស្ត្រាលី ចំនួន ២៥ ភាគរយ ហើយបច្ចុប្បន្ននេះ កំពុងរង់ចាំប្រាក់ដែលបានមកពីការលក់ ភាគហ៊ុននេះ ដើម្បីបើកប្រាក់ឈ្នួលជូនកម្មករនិយោជិត។ ដោយឡែក ភាគីកម្មករនិយោជិតក៏បានលើកឡើងពី ផលវិបាកនៃការមិនបានបើកប្រាក់ឈ្នួលជូនកម្មករនិយោជិតថា បច្ចុប្បន្នកម្មករនិយោជិតកំពុងជំពាក់បំណុលគេ សម្រាប់ជីវភាពរស់នៅរបស់ពួកគាត់។

កថាខណ្ឌទី១ និងទី២ នៃមាត្រា ១១៦ នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ចែងថា ៖ *"ប្រាក់ឈ្នួលនៃកម្មករ ត្រូវបើកយ៉ាងហោចណាស់ ពីរដងក្នុងមួយខែ ដោយមានចន្លោះពេលយ៉ាងច្រើនដប់ប្រាំមួយថ្ងៃ។*

*ប្រាក់ឈ្នួលនៃនិយោជិតត្រូវបើកយ៉ាងហោចណាស់មួយដងក្នុងមួយខែ។"...*។

ក្នុងករណីនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា និយោជកនៅក្នុងសំណុំរឿងនេះមិនបានអនុវត្តស្រប តាមមាត្រា ១១៦ នៃច្បាប់ស្តីពីការងារ នោះទេ ដោយសារច្បាប់ស្តីពីការងារតម្រូវឱ្យការបើកប្រាក់ឈ្នួល ធ្វើឡើង យ៉ាងហោចណាស់ ១ ដង ក្នុងមួយខែ ប៉ុន្តែ និយោជកបែរជាមិនទាន់បានបើកប្រាក់ឈ្នួលសម្រាប់ខែតុលា និងខែវិច្ឆិកា ជូនកម្មករនិយោជិតនៅឡើយ គិតមកត្រឹមថ្ងៃសវនាការ (ថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១៧)។ មិនតែប៉ុណ្ណោះ ភាគីនិយោជកក៏មិនអាចបញ្ជាក់បានថា តើពេលវេលាណាទើបនិយោជកមានលទ្ធភាពក្នុងការផ្តល់ប្រាក់ឈ្នួលជូន កម្មករនិយោជិតតាមរយៈការលក់ភាគហ៊ុន ចំនួន ២៥ ភាគរយ របស់ខ្លួនទៅឱ្យដៃគូជាអ្នកវិនិយោគថ្មីនៅបរទេស។ ភាគីកម្មករនិយោជិតក៏បានលើកឡើងពីផលលំបាករបស់ខ្លួន ដោយសារតែការយឺតយ៉ាវ មិនទាន់ទទួលបានប្រាក់ ឈ្នួលនេះផងដែរ។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា និយោជកមានកាតព្វកិច្ចផ្លូវច្បាប់ក្នុងការទូទាត់ប្រាក់ឈ្នួលក្នុងខែ តុលា និងខែវិច្ឆិកា ឆ្នាំ២០១៧ ជូនកម្មករនិយោជិតតាមការកំណត់នៃច្បាប់ស្តីពីការងារ ដោយមិនអាចលើកយក ហេតុផលណាមួយផ្សេងមកពន្យារពេលបានឡើយ។

ប្រការ ៣៤ នៃប្រកាស ០៩៩ ស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាល ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ ២០០៤ ចែងថា ៖ *"...ក្រុមប្រឹក្សាអាជ្ញាកណ្តាលមានសិទ្ធិ និងអំណាចក្នុងការសម្រេចឱ្យភាគីវិវាទផ្តល់នូវសំណងរដ្ឋប្បវេណី ឬសំណង ខូចខាត ដែលមានលក្ខណៈត្រឹមត្រូវ និងយុត្តិធម៌ ដោយរួមទាំងការៈ-*

*...*

*ខ. បញ្ជាឱ្យបង់ប្រាក់ជាបន្ទាន់នូវប្រាក់ដែលត្រូវបង់..."*។

យោងតាមប្រការ៣៤ នៃប្រកាសលេខ ០៩៩ ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលមានសិទ្ធិបញ្ជាឱ្យនិយោជក បើកប្រាក់ឈ្នួលជូនកម្មករនិយោជិតសម្រាប់ខែតុលា ឆ្នាំ២០១៧ ដែលនៅខ្វះ ៥០ ភាគរយ និងខែវិច្ឆិកា ឆ្នាំ២០១៧ ជាបន្ទាន់។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលកត់សម្គាល់ឃើញថា មាត្រា ១១៧ នៃច្បាប់ស្តីពីការងារដដែល ចែងថា ៖ "*ក្នុងករណីបើកប្រាក់ឈ្នួលយឺតយូរដោយគ្មានសមហេតុផល អធិការការងារត្រូវដាក់កំហិតដល់និយោជក ឱ្យបើកប្រាក់ឈ្នួលទៅឱ្យកម្មករនិយោជិតដោយកំរិតរយៈពេលដែលត្រូវបើកប្រាក់ឈ្នួលនោះ ។*

*កាលណាបើប្រាក់ឈ្នួលនោះ មិនបានបើកក្នុងរយៈពេលដែលបានកំរិតនោះទេ អធិការការងារត្រូវធ្វើកំណត់ហេតុ ហើយបញ្ជូនសំណុំរឿងនេះ ដោយឥតបង់សោហ៊ុយទៅតុលាការមានសមត្ថកិច្ចដែលអាចចាត់គ្រប់វិធានការរក្សាទ្រព្យសម្បត្តិ ទុកជាប្រយោជន៍កម្មករនិយោជិត ព្រមទាំងចាត់តាំងអភិបាលបណ្តោះអាសន្នមួយរូបផងក៏បាន ។*

*បន្ទាប់មក អធិការការងារអាចប្តឹងចោទប្រកាន់គ្រប់បែបយ៉ាង ដើម្បីបង្ខំនិយោជកឱ្យបំពេញកាតព្វកិច្ចចំពោះកម្មករនិងនិយោជិតខ្លួន ។*" ។

ផ្អែកតាមមាត្រា ១១៧ នៃច្បាប់ស្តីពីការងារខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ក្នុងករណីនិយោជកបើកប្រាក់ឈ្នួលជូនកម្មករនិយោជិតដោយមានការយឺតយ៉ាវ អធិការការងារក៏អាចចូលរួមធ្វើអន្តរាគមន៍ដោយកម្រិតកាលកំណត់ឱ្យនិយោជកបង់ប្រាក់ឈ្នួល ក៏ដូចជាកសាង និងបញ្ជូនសំណុំរឿងទៅតុលាការមានសមត្ថកិច្ចដើម្បីចាត់វិធានការបន្ត ក្នុងករណីនិយោជកនៅតែមិនបើកប្រាក់ឈ្នួលជូនកម្មករនិយោជិត។ ហេតុនេះ នៅក្នុងសំណុំរឿងនេះ កម្មករនិយោជិតក៏អាចស្វែងរកអន្តរាគមន៍ពីអធិការការងារ ស្របតាមមាត្រា ១១៧ នៃច្បាប់ស្តីពីការងារនេះផងដែរ ។

សរុបសេចក្តីមក ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេច បង្គាប់ឱ្យនិយោជកបើកប្រាក់ឈ្នួលសម្រាប់ខែតុលា ឆ្នាំ ២០១៧ ដែលនៅខ្វះចំនួន ៥០ ភាគរយ និងខែវិច្ឆិកា ឆ្នាំ២០១៧ ដែលពុំទាន់បានបើក ចំនួន ១០០ ភាគរយ ជូនកម្មករនិយោជិតជាបន្ទាន់ ។

យោងតាមអង្គហេតុ អង្គច្បាប់ និងហេតុផល ដូចបានបញ្ជាក់ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចចេញសេចក្តីបង្គាប់ ដូចតទៅ ៖

## សម្រេច និង បង្គាប់

**ចំណុចវិវាទទី ១ ៖**

- បង្គាប់ឱ្យនិយោជកបើកប្រាក់ឈ្នួលសម្រាប់ខែតុលា ដែលនៅខ្វះ ចំនួន ៥០ ភាគរយ និងខែវិច្ឆិកា ឆ្នាំ២០១៧ ដែលពុំទាន់បានបើក ចំនួន ១០០ ភាគរយ ជូនកម្មករនិយោជិតជាបន្ទាន់ ។

**ប្រភេទនៃសេចក្តីបង្គាប់ ៖ សេចក្តីបង្គាប់មិនជាប់កាតព្វកិច្ច**

*សេចក្តីបង្គាប់នេះ នឹងក្លាយជាស្ថាពរ បន្ទាប់ពីថ្ងៃជូនដំណឹងអំពីសេចក្តីបង្គាប់ចំនួន ០៨ ថ្ងៃ បើសិនជាមិនមានភាគីណាមួយដាក់ពាក្យជំទាស់ជាលាយលក្ខណ៍អក្សរទៅរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ តាមរយៈលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល ក្នុងរយៈពេលនេះទេ ។*

ក្រុមប្រឹក្សាអាជ្ញាកណ្តាល THE ARBITRATION COUNCIL

**ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្តាល**

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីនិយោជក ៖

ឈ្មោះ ៖ **ម៉ារ សំបូរណា**

ហត្ថលេខា ៖ ------------------------------

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីកម្មករនិយោជិត ៖

ឈ្មោះ ៖ **អន ណាន**

ហត្ថលេខា ៖------------------------------

ប្រធានក្រុមអាជ្ញាកណ្តាល ៖

ឈ្មោះ ៖ **សុខ ម៉ាឌឿង**

ហត្ថលេខា ៖ ------------------------------